Res. 49/199

# សេចក្ដីសំរេចចិត្ត

## ស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា

មហាសន្និបាតនៃអង្គការសហប្រជាជាតិៈ

អនុលោមតាម គោលការណ៍ណែនាំ និងគោលបំណងនានាដែលមានចែងនៅក្នុងធម្មនុញ្ញនៃអ.ស.ប. សេចក្ដីថ្លែងការណ៍ជាសកលស្ដីអំពីសិទ្ធិមនុស្ស ១/ និងកតិកាសញ្ញាទាំងឡាយស្ដីពីសិទ្ធិមនុស្ស ២/ ។

តាមការធ្វើកំណត់សំគាល់ ចំពោះកិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួម នៃបញ្ហាទំនាស់របស់ប្រទេសកម្ពុជា ៣/ ដែលបានចុះកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសកាលពីថ្ងៃទី ២៣ តុលា ១៩៩១ ដោយនៅក្នុងនោះមានរួមបញ្ចូលផ្នែកទី៣ ដែលមានទំនាក់ទំនងនឹងសិទ្ធិមនុស្ស ។

ដោយរំលឹកឡើងវិញ នូវសេចក្ដីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ ១៩៩៤ ៦១ ចុះថ្ងៃទី ៤ មិនា ១៩៩៤ ៤/ និងសេចក្ដីសំរេចចិត្តនៃមហាសន្និបាត អ.ស.ប. ៤៨ ១៥៤ និងសេចក្ដីសំរេចចិត្តពាក់ព័ន្ធមុនៗជាច្រើនទៀត ដោយមានរួមបញ្ចូលនូវសេចក្ដីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ ១៩៩៣ ៦ ចុះនៅថ្ងៃទី ១៩ កុម្ភៈ ១៩៩៣ ៣/ ដែលបានស្នើសុំឲ្យមានការចាត់តាំង អ្នកតំណាងពិសេសម្នាក់របស់លោកអគ្គលេខាធិការនៃអ.ស.ប.ប្រចាំប្រទេសកម្ពុជា ហើយនៅពេលបន្ទាប់មក ការចាត់តាំងអ្នកតំណាងពិសេសនេះ ក៏បានរៀបចំឲ្យមានឡើងដោយលោកអគ្គលេខាធិការ នៃ អ.ស.ប. ។

ដោយចងចាំទុក អំពីតួនាទីនិងការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ នៅក្នុងការស្ដាបនា និងកសាងប្រទេសកម្ពុជាឡើងវិញ ។

ដោយយល់ឃើញថា ប្រវត្តិសាស្ដ្រដ៏ខ្លោចផ្សានៃប្រទេសកម្ពុជាកន្លងទៅថ្មីៗនេះតំរូវឲ្យមានវិធានការពិសេសជាច្រើន ដើម្បីធានានូវកិច្ចការពារ និងលើកស្ទួយសិទ្ធិមនុស្សដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា និងធានាមិនឲ្យមានការវិលត្រឡប់មកវិញនូវរបបនយោបាយនិងការអនុវត្តន៍ពីអតីតកាល ដូចមានចែកទុកនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស កាលពីថ្ងៃទី ២៣ តុលា ១៩៩១ ៣/ ។

ដោយស្វាគមន៍ ចំពោះការបង្កើតឲ្យមានការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា ។

១. សូមលើកសំណើជូន លោកអគ្គលេខាធិការ សុំឲ្យធានានូវការការពារសិទ្ធិមនុស្សដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងធានាឲ្យមានធនធានគ្រប់គ្រាន់ យកមកពីធនធានដែលមានស្រាប់របស់អ.ស.ប. សំរាប់ជាជំនួយឧបត្ថម្ភដល់ដំណើរការនៃកិច្ចប្រតិបត្តិការរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ។

២. សូមស្វាគមន៍ ចំពោះរបាយការណ៍របស់លោកអគ្គលេខាធិការអ.ស.ប. ដែលបានដាក់ជូនមហាសន្និបាត ស្តីអំពីតួនាទីរបស់ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្ស ចំពោះការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងកិច្ចការពារនិងលើកស្ទួយសិទ្ធិមនុស្ស [៦] ។

៣. សូមស្វាគមន៍ផងដែរ ចំពោះទស្សនកិច្ចរបស់អគ្គស្នងការសិទ្ធិមនុស្ស នៃអ.ស.ប. នៅក្នុងប្រទេសកម្ពុជា ។

៤. សូមស្វាគមន៍ និងសរសើរលើកទឹកចិត្ត ចំពោះការខិតខំប្រឹងប្រែងរបស់បុគ្គល អង្គការក្រៅរដ្ឋាភិបាល អង្គការរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ដែលមានជាប់ទាក់ទងទៅនឹងសកម្មភាពសិទ្ធិមនុស្សទាំងអស់នៅក្នុងប្រទេសកម្ពុជា ។

៥. សូមធ្វើកំណត់សំគាល់ព្រមទាំងការសរសើរ អំពីរបាយការណ៍ស្តីពីស្ថានការណ៍សិទ្ធិមនុស្សនៅប្រទេសកម្ពុជា ដែលបានដាក់ជូនមហាសន្និបាត ដោយលោកតំណាងពិសេសរបស់លោកអគ្គលេខាធិការអ.ស.ប. [៧] និងយល់ព្រមទៅនឹងយោបល់ស្នើ និងសេចក្តីសន្និដ្ឋានរបស់គាត់ ដែលនៅក្នុងនោះមានរួមបញ្ចូលទាំងយោបល់ស្នើទាំងឡាយណាដែលមានចំណង :

ក. ធ្វើការធានាដល់ឯករាជ្យភាពនៃតុលាការ និងការបង្កើតឲ្យមានក្បួនច្បាប់ត្រឹមត្រូវ ។

ខ. ធ្វើការលើកស្ទួយដល់ការយោគយល់គ្នាអំពីពហុវប្បធម៌ និងការសុខចិត្តទទួលនូវជាតិពន្ធផ្សេងគ្នាដែលមាននៅក្នុងប្រទេសកម្ពុជា ។

៦. សូមលើកសំណើជូន លោកតំណាងពិសេសរបស់លោកអគ្គលោខាធិការ ក្នុងកិច្ចរួមប្រាស្រ័យការងារជាមួយនឹងការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សប្រចាំកម្ពុជា សុំឲ្យធានាព័ប់រង

ដល់ការវាយតម្លៃចំពោះយោបល់ស្នើ ដែលធ្វើឡើងដោយលោកតំណាងពិសេសនៅក្នុងរបាយការណ៍របស់គាត់ ៧/ និង យោបល់ស្នើនានា ដែលមាននៅក្នុងរបាយការណ៍លើកទីមួយរបស់គាត់ ៨/ ដែលគេកំពុងប្រព្រឹត្តិនិងអនុវត្តន៍តាម ។

៧. សូមលើកសំណើជូន លោកអគ្គលេខាធិការ សុំឲ្យជួយឧបត្ថម្ភគ្រប់រាល់ធនធាន ដែលត្រូវការចាំបាច់ យកមកពីថវិកាដែលមានជាធម្មតារបស់អ.ស.ប. ដើម្បីធ្វើឲ្យលោកតំណាងពិសេស មានលទ្ធភាពបន្តនិងបំពេញការងាររបស់គាត់យ៉ាងរួសរាន់បំផុត ។

៨. សូមស្វាគមន៍ ចំពោះការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជាក្នុងកិច្ចការពារនិងលើកស្ទួយសិទ្ធិមនុស្ស ដែលនៅក្នុងនោះ មានរួមបញ្ចូលទាំងវិធានការក្នុងវិស័យអប់រំសិទ្ធិមនុស្ស និង ការសិក្សាច្បាប់ ។

៩. សូមស្វាគមន៍ផងដែរ ចំពោះការរីកចំរើននៃលក្ខណៈភាពរបស់ពន្ធនាគារ និងការបង្កើតឲ្យមានប្រព័ន្ធការងារនៃតុលាការយ៉ាងត្រឹមត្រូវ និងសូមជំរុញឲ្យមានការខិតខំប្រឹងប្រែងអនុវត្តកិច្ចការទាំងអស់នេះជាបន្តទៅទៀត ។

១០. សូមសម្តែងនូវការបារម្ភយ៉ាងខ្លាំង ចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដូចដែលលោកតំណាងពិសេសបានរាយការណ៍ជាពិស្តារនៅក្នុងរបាយការណ៍របស់គាត់ និងសូមដាស់តឿនដល់រដ្ឋាភិបាលកម្ពុជាសុំឲ្យធ្វើការអង្កេតយ៉ាងហ្មត់ចត់ច្បាស់លាស់ទៅលើក្តីចោទប្រកាន់នានា ស្តីពីការរំលោភសិទ្ធិមនុស្ស និងសូមឲ្យធ្វើការកាត់ទោសតាមទម្រង់ការនៃច្បាប់ ដល់ជនជាប់ចោទទាំងឡាយណាដែលមានកំហុសស្តីពីបទរំលោភសិទ្ធិមនុស្ស ។

១១. សូមសម្តែងនូវការបារម្ភយ៉ាងខ្លាំងផងដែរ ចំពោះអំពើយង់ឃ្នងព្រៃផ្សៃដែលប្រព្រឹត្តដោយក្រុមក្រៅច្បាប់ខ្មែរក្រហម ដែលនៅក្នុងនោះ មានរួមបញ្ចូលការសម្លាប់រង្គាលរបស់ពួកគេទៅលើអ្នកស្រុកប្រហែលជិតហាសិបនាក់នៅក្នុងខេត្តបាត់ដំបង កាលពីខែ តុលា ១៩៩៤ គ្រោះថ្នាក់នៃការចាប់ខ្លួនអ្នកស្រុក ការចាប់ខ្លួនជនឈ្លើយសឹកបរទេសយកទៅសម្លាប់ចោល និងគ្រោះថ្នាក់ដែលគួរឲ្យសោកស្តាយផ្សេងៗទៀត ដូចដែលមានចែងជាពិស្តារនៅក្នុងរបាយការណ៍របស់លោកតំណាងពិសេស។

១២. ផ្តន្ទាដោយគ្មានកែប្រែ ចំពោះគ្រប់រាល់ការគំរាមកំហែងរបស់ក្រុមក្រៅច្បាប់ខ្មែរក្រហមទៅលើសុវត្ថិភាពរបស់ជនទាំងឡាយណា ដែលពាក់ព័ន្ធនឹងគ្រប់សកម្មភាពជំនួយខាងការអភិវឌ្ឍន៍តាមជនបទនៃប្រទេសកម្ពុជា ។

១៣. សូមសម្តែងនូវការបារម្ភយ៉ាងខ្លាំង ចំពោះការប្រើប្រាស់មីនដាក់ក្នុងដីដោយគ្មានរបៀប និងបញ្ហាវិនាសកម្ម និងអស្ថេរភាពដោយសារតែគ្រាប់មីនទាំងឡាយនោះ ដែលកើតមានឡើងគ្មានឈប់ឈរនៅប្រទេសកម្ពុជា និងសូមលើកទឹកចិត្តជាស់តឿនដល់រដ្ឋាភិបាលកម្ពុជា សុំឲ្យបន្តការគាំទ្ររបស់ខ្លួនចំពោះកម្មវិធីដោះមីនទាំងនោះ ។

១៤. សូមអំពាវនាវដល់ រដ្ឋាភិបាលកម្ពុជាធ្វើសេចក្តីសង្កេតនិងអនុវត្តសិទ្ធិមនុស្ស ចំពោះប្រជាពលរដ្ឋគ្រប់រូប តាមសាលក្រមណាដែលមានលក្ខណៈស្របទឹងកតិការអន្តរជាតិ និងឯកសារស្តីពីសិទ្ធិមនុស្សផ្សេងៗទៀត ដែលប្រទេសកម្ពុជាបានអនុម័តយល់ព្រមចូលជាភាគី ។

១៥. សូមលើកសំណើជូន រដ្ឋាភិបាលកម្ពុជាសុំឲ្យបំពេញករណីយកិច្ចធ្វើរបាយការណ៍ដែលមានចែងកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិឲ្យបានទៀងទាត់ ។ ធ្វើការទាក់ទាញយកជំនួយពីការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សប្រចាំកម្ពុជាដើម្បីជួយរៀបចំធ្វើរបាយការណ៍ឲ្យបានត្រឹមត្រូវ។

១៦. សូមលើកទឹកចិត្តជាស់តឿន ដល់រដ្ឋាភិបាលកម្ពុជាសុំឲ្យអនុម័តច្បាប់សារពត៌មានមួយដែលមានលក្ខណៈស្របទៅនឹងគំរូច្បាប់អន្តរជាតិ ហើយអាចលើកស្ទួយដល់ការទទួលខុសត្រូវខាងសារពត៌មាន នៅពេលដែលកំពុងតែការពារសេរីភាពក្នុងការបញ្ចេញមតិ ។

១៧. សូមលើកសំណើជូន មជ្ឈមណ្ឌលសិទ្ធិមនុស្ស ព្រមជាមួយនឹងកិច្ចព្រមព្រៀង និងសហការពីរដ្ឋាភិបាលកម្ពុជា សុំឲ្យជួយផ្តល់ជំនួយជាទិភទនិងខាងបច្ចេកទេស ចំពោះការបង្កើតឲ្យមានស្ថាប័នជាតិឯករាជ្យមួយ សំរាប់ការពារនិងលើកស្ទួយសិទ្ធិមនុស្ស ដូចជាអង្គការអំប៊ុដសម៉ែន [illegible] ឬគណៈកម្មការសិទ្ធិមនុស្សជាដើម ។

១៨. សូមសរសើរដល់ ការខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិនុស្សអ.ស.ប. ប្រចាំកម្ពុជា ក្នុងការជួយនិងឧបត្ថម្ភដល់រដ្ឋាភិបាលកម្ពុជា ក៏ដូចគ្នានឹងការជួយឧបត្ថម្ភដល់អង្គការក្រៅរដ្ឋាភិបាលនានា និងអង្គការផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងកិច្ចការពារ និងលើកស្ទួយសិទ្ធិមនុស្ស ក្នុងកិច្ចសហការជាមួយនិងរដ្ឋាភិបាលកម្ពុជា ហើយនិងសូមផ្តន្ទាដោយគ្មានកែប្រែ ដល់ការវាយប្រហារនានាទៅលើពួកអង្គការរស់ទាំងនោះ ។

១៩. សូមធ្វើកំណត់សំគាល់ដោយសរសើរ ចំពោះការប្រើប្រាស់ប្រាក់បេឡាអ.ស.ប.សំរាប់កម្មវិធីសិក្សាអប់រំសិទ្ធមនុស្សនៅប្រទេសកម្ពុជា ដោយលោកអគ្គលេខាធិការដើម្បីឧបត្ថម្ភជាថវិកាដល់កម្ម

វិធីសកម្មភាពរបស់ការិយាល័យនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សប្រចាំកម្ពុជា ដូចដែលបានចែងកំណត់នៅក្នុងសេចក្តីសំរេចចិត្តនានាស្តីពីសិទ្ធិមនុស្សនៃមហាសន្និបាតនៃអ.ស.ប. និងនៃគណៈកម្មការសិទ្ធិមនុស្ស ។

២០. សូមលើកសំណើជូន មជ្ឈមណ្ឌលសិទ្ធិមនុស្ស ក្នុងកិច្ចសហការជាមួយនឹងភ្នាក់ងារឯកទេស និងកម្មវិធីអភិវឌ្ឍន៍នានា សុំឲ្យបង្កើតនិងអនុវត្តកម្មវិធីទាំងឡាយនោះ ព្រមជាមួយនឹងកិច្ចព្រមព្រៀង និងសហការពីរដ្ឋាភិបាលកម្ពុជា ទៅលើតំបន់អាទិភាពនានាដែលបានគូសបញ្ជាក់ឡើងដោយលោកតំណាងពិសេស ។ សូមឲ្យគិតគូយកចិត្តទុកដាក់ចំពោះស្ត្រី និងក្រុមនានា ដែលកំពុងស្ថិតក្នុងសភាពឈឺចាប់លំបាកវេទនា ដោយនៅក្នុងនោះមានរួមបញ្ចូលទាំងកុមារ និងជនភៀសខ្លួនទៀតផង ។

២១. សូមលើកសំណើជូន លោកអគ្គលេខាធិការនៃអ.ស.ប. សុំឲ្យរាយការណ៍ជូនមហាសន្និបាតនាសម័យប្រជុំលើកទីហាសិប ស្តីពីតួនាទីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សក្នុងការជួយដល់ប្រជាពលរដ្ឋនិងប្រទេសកម្ពុជាចំពោះការការពារ និងលើកស្ទួយសិទ្ធិមនុស្ស និងស្តីពីយោបល់ស្នើនានាដែលលើកឡើងដោយលោកតំណាងពិសេស អំពីគ្រប់រាល់បញ្ហាដែលស្ថិតនៅក្នុងរង្វង់អាណត្តិរបស់គាត់ ។

២២. សូមសំរេច បន្តការយកចិត្តទុកដាក់ពិនិត្យពិចារណា ទៅលើស្ថានការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា នាសម័យប្រជុំរបស់ខ្លួនលើកទីហាសិបនៃមហាសន្និបាតអ.ស.ប. ។

អនុម័តដោយគ្មានសន្លឹកឆ្នោត

### 1993/254. Situation des droits de l'homme au Cambodge

A sa 44e séance plénière, le 28 juillet 1993, le Conseil économique et social, prenant note de la résolution 1993/6 de la Commission des droits de l'homme, en date du 19 février 1993[49], a approuvé la décision de la Commission de prier le Secrétaire général :

*a*) D'assurer, après l'expiration du mandat de l'Autorité provisoire des Nations Unies au Cambodge, le maintien dans ce pays d'une présence des Nations Unies au titre des droits de l'homme;

*b*) De fournir, dans les limites des ressources globales dont dispose l'Organisation des Nations Unies, les moyens supplémentaires voulus pour financer la présence opérationnelle du Centre pour les droits de l'homme du Secrétariat dans le cadre d'autres activités de l'Organisation dans le pays après l'expiration du mandat de l'Autorité provisoire des Nations Unies au Cambodge;

*c*) De désigner un représentant spécial chargé :

i) De maintenir les contacts avec le Gouvernement et le peuple cambodgiens;

ii) D'orienter et de coordonner la présence des Nations Unies au titre des droits de l'homme au Cambodge;

iii) D'aider le Gouvernement à promouvoir et protéger les droits de l'homme;

iv) De faire rapport à l'Assemblée générale, lors de sa quarante-huitième session, et à la Commission des droits de l'homme, lors de sa cinquantième session.

### 1993/254. Situation of human rights in Cambodia

At its 44th plenary meeting, on 28 July 1993, the Economic and Social Council, taking note of Commission on Human Rights resolution 1993/6 of 19 February 1993,[19] approved the Commission's requests to the Secretary-General:

(*a*) To ensure a continued United Nations human rights presence in Cambodia after the expiry of the mandate of the United Nations Transitional Authority in Cambodia;

(*b*) To provide appropriate additional resources, within existing overall United Nations resources, to fund the operational presence of the Centre for Human Rights of the Secretariat within the framework of other United Nations activities in Cambodia after the expiry of the mandate of the United Nations Transitional Authority in Cambodia;

(*c*) To appoint a special representative:

(i) To maintain contact with the Government and the people of Cambodia;

(ii) To guide and coordinate the United Nations human rights presence in Cambodia;

(iii) To assist the Government in the promotion and protection of human rights;

(iv) To report to the General Assembly at its forty-eighth session and the Commission on Human Rights at its fiftieth session.